ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៦០ ឌ.ក្រ.ច-២០០២

# លេខាធិការ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

## ជម្រាបមក

### លោក លោកស្រី ប្រធាន និងព្រះរាជអាជ្ញា នៃតុលាការគ្រប់ខេត្ត ក្រុង

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការបែងចែកសំណុំរឿងនៅតាមតុលាការ និង អយ្យការ ខេត្ត-ក្រុង ។

ខ្ញុំសូមជម្រាបលោក លោកស្រីថា នាសម័យប្រជុំ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០០២ ឧត្តមក្រុមប្រឹក្សនៃអង្គចៅក្រម បានពិនិត្យ និងពិភាក្សាយ៉ាងយចិត្តទុកដាក់ពីបញ្ហាកកស្ទះសំណុំរឿងនៅតាមតុលាការ-អយ្យការខេត្ត-ក្រុងមួយចំនួន អង្គប្រជុំបានពិនិត្យឃើញថា មូលហេតុនៃការកកស្ទះនេះបណ្តាលមក មួយចំនួនពីការបែងចែកសំណុំរឿងរបស់លោក លោកស្រី ប្រធានតុលាការ និង ព្រះរាជអាជ្ញា ។

ដែរដើម្បីអោយការងារក្នុងវិស័យយុត្តាធិការរបស់យើងមានភាពរលូនមិនកកស្ទះ សម័យប្រជុំបានសម្រេចសុំអោយលោក លោកស្រី ដែលជាប្រធាន និងព្រះរាជអាជ្ញាគ្រប់ខេត្ត-ក្រុង យកចិត្តទុកដាក់បែងចែកសំណុំរឿងជូនអស់លោក លោកស្រី ជាចៅក្រម និងជាព្រះរាជអាជ្ញារង អោយមានតុល្យភាពតាមចំនួនសំណុំរឿង និងសមត្ថភាព ជៀសវាងការបែងចែកតាមមនោសញ្ចេតនា គឺអស់លោក លោកស្រីខ្លះមានរឿងច្រើនធ្វើមិនអស់ហើយអស់លោក លោកស្រីខ្លះ ពុំមានរឿងធ្វើ ។

អាស្រ័យហេតុនេះ សូមលោក លោកស្រី ជាប្រធាន និងព្រះរាជអាជ្ញា នៃតុលាការគ្រប់ខេត្ត-ក្រុង ថ្មីទាំងអស់មេត្តាអនុវត្តតាមសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ។

សូមលោក លោកស្រីទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២

**ឡៅ មួន**

ចម្លងជូន
-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
-ប្រធានតុលាការកំពូល
-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
-ប្រធានសាលាឧទ្ធរណ៍
-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
" ដើម្បីជូនជ្រាប "